- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

1

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៧ សសរ

# សេចក្ដីសំរេច

## ស្ដីពីការបង្កើតគណៈកម្មការចំរុះ សំរាប់សិក្សា និងវាយតំលៃលើគំរោងវិនិយោគស្ដារ និងអភិវឌ្ឍន៍ រមណីយដ្ឋានតំបន់ប្រាសាទព្រះវិហារ និងប្រាសាទសំបូរព្រៃគុហ៍ សំរាប់បំរើ សំណូមពរវិនិយោគ របស់ក្រុមហ៊ុន SOKHA HOTEL CO., LTD.

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្ដីពីការអនុវត្តន៍ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្ដីពីការធ្វើវិសោធនកម្មលើ អនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទិ ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧
- យោងស្មារតីអង្គប្រជុំ "ច្រកចេញ-ចូលតែមួយ" នៃក.អ.ក "គ.វ.ក" នាថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០២
- តាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

# សំរេច

**ប្រការ១:** បង្កើតគណៈកម្មការចំរុះ ដើម្បីសិក្សា និងវាយតំលៃលើគំរោងវិនិយោគស្ពារ និងអភិវឌ្ឍន៍រមណីយដ្ឋាន តំបន់ប្រាសាទព្រះវិហារ និងប្រាសាទសំបូរព្រៃគុហ៍ សំរាប់បំរើសំណូមពរវិនិយោគ របស់ក្រុមហ៊ុន SOKHA HOTEL CO., LTD. ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម **ឌី យ៉ាវ** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ប្រធាន |
| ២- ឯកឧត្តម **គង់ វិបុល** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- ឯកឧត្តម **វ៉ា គឹមហុង** | ប្រធានគណៈកម្មាធិការកិច្ចការព្រំដែនកម្ពុជា-ថៃ | អនុប្រធាន |
| ៤- ឯកឧត្តម **ជុច ភឿន** | អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៥- ឯកឧត្តម **ព្រុំ សុខា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៦- ឯកឧត្តម **សុខ ចិន្តា** | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៧- ឯកឧត្តម **វស់ រ៉េន** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៨- ឯកឧត្តម **រ័ត្ន សណ្តាប់** | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៩- ឯកឧត្តម **សេង លឹមនៅ** | អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១០ - ឯកឧត្តម **ដោក ណារិន** | អនុរដ្ឋលេខាធិការ ក្រសួងធម្មការ និងកិច្ចការសាសនា | សមាជិក |
| ១១ - ឯកឧត្តម **ព្រាប តាន់** | អភិបាលខេត្តព្រះវិហារ | សមាជិក |
| ១២ - ឯកឧត្តម **នូ ភឿង** | អភិបាលខេត្តកំពង់ធំ | សមាជិក |
| ១៣- ឯកឧត្តម **ឆេព ហែន** | អគ្គនាយករងអាជ្ញាធរអប្សរា | សមាជិក |
| ១៤ - លោក **បុង ម៉ុនហួន** | ប្រធាននាយកដ្ឋាន ក្រុមប្រឹក្សាភិវឌ្ឍន៍កម្ពុជា | លេខាធិការ |

សមាជិកគណៈកម្មការទាំងអស់ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធាន ក្នុងករណីប្រធានអវត្តមាន ។

**ប្រការ២:** គណៈកម្មការនេះ មានភារកិច្ចដូចតទៅ :

ក- ចុះសិក្សាស្រាវជ្រាវដល់ទីកន្លែងជាក់ស្តែងនូវបញ្ហាចំពោះមុខបច្ចុប្បន្ន អំពីផលដែលអាចនាំអោយមានការប្រែប្រួលបរិស្ថាន នៅតំបន់ប្រាសាទព្រះវិហារ និងគោលការណ៍រក្សាស្ថានភាពដដែលមុនពេលបោះបង្គោលព្រំដែនជាស្ថាពរ ។

ខ- សិក្សា និងវាយតំលៃលើទិដ្ឋភាពច្បាប់-បច្ចេកទេសពាក់ព័ន្ធដល់គំរោងវិនិយោគស្ពារ និងអភិវឌ្ឍន៍រមណីយដ្ឋានទាំង០២ខាងលើ ដូចមានចែងក្នុងប្រការ១ ដើម្បីធ្វើជាមូលដ្ឋានសំរាប់ការពិនិត្យសំរេចក្នុងអង្គប្រជុំ "ច្រកចេញ-ចូលតែមួយ" លើសំណើស៊ីវិនិយោគរបស់ក្រុមហ៊ុន SOKHA HOTEL CO., LTD.នេះ នាពេលខាងមុខម្តងទៀត ។

ក្នុងករណីសំណើស៊ីវិនិយោគរបស់ក្រុមហ៊ុននេះ ត្រូវបានអនុញ្ញាតអោយវិនិយោគដោយមានការលើកទឹកចិត្តនោះ គណៈកម្មការនេះត្រូវមានភារកិច្ចបន្ត ដូចខាងក្រោម:

- រៀបចំបែបបទ ឯកសារគតិយុត្តិ-កំណត់ផែនការសកម្មភាព ព្រមទាំងរៀបចំប្លង់គោលអភិវឌ្ឍន៍រមណីយដ្ឋានទេសចរណ៍ធម្មជាតិវប្បធម៌ទាំង២កន្លែង "តំបន់ប្រាសាទព្រះវិហារ- ប្រាសាទសំបូរព្រៃគុក" អោយបានច្បាស់លាស់ ដើម្បីធានាការគ្រប់គ្រង និងថែរក្សាតំបន់ប្រាសាទអោយបានល្អតាមលំនាំនៃព្រះរាជក្រឹត្យ ស្តីពីការបង្កើតរមណីយដ្ឋានភ្នំព្រះរាជទ្រព្យកន្លងមក ។
- តាមដានជាប្រចាំ នូវរាល់ការអនុវត្តការងាររបស់ក្រុមហ៊ុន តាមជំហានទីមួយៗ ។
- លើកសំណើ សុំការសំរេចពីរាជរដ្ឋាភិបាល ចំពោះករណីដែលហួសពីសមត្ថកិច្ចរបស់ខ្លួន ។
- រាយការណ៍អំពីលទ្ធផលការងារជាបន្តបន្ទាប់ជូនរាជរដ្ឋាភិបាល ។

**ប្រការ៣ៈ** គណៈកម្មការនេះ មានការិយាល័យអចិន្ត្រៃយ៍តាំងនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដោយមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សំរាប់អនុវត្តការងារ ។

**ប្រការ៤ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី-សហរដ្ឋមន្ត្រីក្រសួងក្រសួងមហាផ្ទៃ - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ-រដ្ឋមន្ត្រីក្រសួងទេសចរណ៍-រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់- រដ្ឋមន្ត្រីក្រសួងបរិស្ថាន-រដ្ឋមន្ត្រីក្រសួងធម្មការ និងកិច្ចការសាសនា-ប្រធាន "ក.អ.ក" -រដ្ឋមន្ត្រីគ្រប់ក្រសួង-ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀង១ខ្លួន អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ០២ សរ.ណន

## សារាចរណែនាំ

### ស្តីពីការចាត់បញ្ជូនប្រធានមន្ទីរអង្គភាពជំនាញនានា ជុំវិញខេត្ត-ក្រុង ទៅចូលរួមសិក្សារយៈពេលវែងនៅក្នុងប្រទេស និងក្រៅប្រទេស

ផ្អែកតាមមាត្រា ២២ នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងមាត្រា៤ នៃច្បាប់ ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ របស់ខេត្ត-ក្រុង និងផ្អែកតាមខ្លឹមសារនៃសារាចរណែនាំ លេខ ១០ សរ.ណន ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាលបានកំណត់ថា អភិបាលខេត្ត-ក្រុង ជាតំណាងរបស់រដ្ឋបាលកណ្តាលនៅក្នុងមណ្ឌលដែនដីរបស់ខ្លួន មានភារកិច្ចក្នុងការសំរុះសំរួលតម្រង់ទិសដៅ ជំរុញតាមដានការអនុវត្តន៍ និងមានភារកិច្ចជាអ្នកផ្តល់យោបល់ទៅលើកិរិយាមារយាទ ការគោរពវិន័យ សាមគ្គីភាពរបស់ប្រធានមន្ទីរ អង្គភាពនានា និងជាអ្នកចូលរួមពិគ្រោះយោបល់ជាមួយក្រសួង-ស្ថាប័ននានា លើបេក្ខជនដែលត្រូវតែងតាំងជាប្រធានមន្ទីរអង្គភាពជំនាញនានានៅខេត្ត-ក្រុង ។

កន្លងមករាជរដ្ឋាភិបាលបានសង្កេតឃើញថា រាល់ការតែងតាំងប្រធានមន្ទីរអង្គភាពនានា នៅតាមខេត្ត ក្រុង សុទ្ធតែត្រូវបានពិគ្រោះយោបល់ និងមានការឯកភាពគ្នារវាងក្រសួង-ស្ថាប័នសាមី និងអភិបាលខេត្ត-ក្រុងសាមីទាំងអស់ ។ ដោយឡែក ចំពោះការចាត់បញ្ជូនប្រធានមន្ទីរអង្គភាពជំនាញនានាក្រោមឱវាទទៅចូលរួមសិក្សារយៈពេលវែងនៅក្នុង និងក្រៅប្រទេស ក្នុងរយៈពេលកន្លងមក ក្រសួង-ស្ថាប័នសាមីខ្លះ ពុំបានធ្វើការពិគ្រោះយោបល់ និងមានការឯកភាពពីអភិបាលខេត្ត - ក្រុងសាមីនិមួយៗ ជាមុនទេ ។

ដោយមើលឃើញពីការលំបាករបស់អភិបាលខេត្ត-ក្រុងនិមួយៗ ក្នុងការគ្រប់គ្រងដែនដី នៃខេត្ត-ក្រុងរបស់ខ្លួន និងដើម្បីធានាអោយបាននូវយន្តការគ្រប់គ្រងរដ្ឋបាល និងនយោបាយទូទៅក្នុងដែនដីអោយដំណើរការមានប្រក្រតីភាព និងមានប្រសិទ្ធភាពខ្ពស់ រាជរដ្ឋាភិបាលដាក់បទបញ្ជាអោយក្រសួង-ស្ថាប័ននិមួយៗមុននឹងធ្វើការចាត់បញ្ជូនប្រធានមន្ទីរអង្គភាពជំនាញនានានៅតាមខេត្ត-ក្រុង ទៅចូលរួមសិក្សារយៈពេលវែងនៅក្នុង និងក្រៅប្រទេស ចាំបាច់ត្រូវមានការពិគ្រោះយោបល់អោយបានឯកភាពពីអភិបាលខេត្ត-ក្រុងសាមីនិមួយៗ ជាមុនសិន ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង-ស្ថាប័ន និងខេត្ត-ក្រុង ត្រូវខិតខំអនុវត្ត អោយទទួលបានលទ្ធផលល្អ ដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

ចំលងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលាខេត្ត-ក្រុង
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខៈ ២០៩ សហវ

# ប្រកាស
# ស្ដីពី
# ការរៀបចំ និង ការប្រព្រឹត្តទៅ
# នៃអង្គភាពសវនកម្មផ្ទៃក្នុងរបស់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ជស/រកម/១៣០០/១០ ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០០០ ដែលប្រកាសច្បាប់ស្ដីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/៩៤/០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៨/៨៨ ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំង ឥស្សរជនជាអនុរដ្ឋលេខាធិការនៃក្រសួងនិង រដ្ឋលេខាធិការដ្ឋាននៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញ អនុក្រិត្យលេខ ០៤/អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ដោយរងចាំការអនុម័ត អនុក្រិត្យស្ដីពី ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ អង្គភាពសវនកម្មផ្ទៃក្នុង តាមតំរូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**ប្រការ ១** : អនុលោមតាមមាត្រា ៤១ ជំពូកទី ៩ នៃព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែមិនា ឆ្នាំ ២០០០ ដែលបានប្រកាសឱ្យប្រើច្បាប់ស្ដីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសនេះ បង្កើតឡើង និងកំណត់មុខងាររបស់អង្គភាពសវនកម្មផ្ទៃក្នុងបណ្ដោះអាសន្នរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៅតាមបណ្ដាក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ដើម្បីដំណើការក្នុងការអនុវត្តន៍ការងារចាំបាច់និងជាបន្ទាន់ លើការត្រួតពិនិត្យការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋរបស់គ្រប់បណ្ដា ក្រសួង - ស្ថាប័ន ខេត្ត- ក្រុង និងសហគ្រាសសាធារណៈ ។

**ប្រការ ២** : កិច្ចដំណើរការនៃអង្គភាពសវនកម្មផ្ទៃក្នុងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចអនុវត្តតាមខ្លឹមសារនៃមាត្រា ៧ នៃអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងប្រកាសលេខ ១០១ សហវ- ប្រក ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០១ និងប្រកាសលេខ ១៥៤ សហវ- ប្រក ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គាធិការដ្ឋាន ។

**ប្រការ ៣** : អង្គភាពសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលខុសត្រូវអនុវត្តមុខងារឯករាជ្យដើម្បីពិនិត្យ និងវាយតំលៃសកម្មភាពរបស់អង្គភាពគ្រប់បណ្ដាក្រសួង- ស្ថាប័ន ខេត្ត- ក្រុង និង សហគ្រាសសាធារណៈ ។

ការធ្វើសវនកម្មផ្ទៃក្នុង គឺមានគោលដៅជួយអោយគ្រប់បណ្ដាក្រសួង- ស្ថាប័ន ខេត្ត- ក្រុង និង សហគ្រាសសាធារណៈ បំពេញការទទួលខុសត្រូវរបស់ខ្លួន អោយមានប្រសិទ្ធភាព ។ គោលដៅចុងក្រោយរបស់សវនកម្មផ្ទៃក្នុង គឺ ផ្ដល់នូវការវិភាគ ការវាយតំលៃ អនុសាសន៍ មតិយោបល់ និងពត៌មានទាក់ទង នឹងសកម្មភាព ដែលបានត្រួតពិនិត្យ និង ពិនិត្យឡើងវិញ ។

ដើម្បីអនុវត្តភារកិច្ចនិងការទទួលខុសត្រូវរបស់ខ្លួន សវនកររបស់អង្គភាពសវនកម្មផ្ទៃក្នុងត្រូវមានសិទ្ធិពេញលេញ សេរីភាពគ្រប់គ្រាន់ក្នុងការចូលត្រួតពិនិត្យ ដោយគ្មានការរារាំង ហាមឃាត់នូវគ្រប់សកម្មភាព រាល់បញ្ជីកត់ត្រា រាល់ទ្រព្យសម្បត្តិ និងបុគ្គលិករបស់អង្គភាព ដែលមានការពាក់ព័ន្ធ ។

**ប្រការ ៤:** មុខងារនិងការទទួលខុសត្រូវរបស់អង្គភាពសវនកម្មផ្ទៃក្នុងមានដូចខាងក្រោម :

១-ពិនិត្យឡើងវិញលើមុខងារ សកម្មភាព កិច្ចប្រតិបត្តិការ និងកម្មវិធីរបស់អង្គភាពក្នុងការិយបរិច្ឆេទ សមស្រប ដើម្បីកំណត់វាយតំលៃលើការបង្កើតផែនការ ការតម្រង់ទិស ការចាត់ចែង និងការត្រួតពិនិត្យ ដោយផ្អែកតាមគោលការណ៍ណែនាំ គោលនយោបាយ និងនីតិវិធីនៃការគ្រប់គ្រងអោយបានត្រឹមត្រូវតាមគោលដៅរបស់អង្គភាព និងការអនុវត្តន៍ស្តង់ដាររដ្ឋបាល ។

២-កំណត់នូវភាពសមស្របគ្រប់គ្រាន់ និងភាពសំរេចផលល្អលើប្រព័ន្ធត្រួតពិនិត្យគណនេយ្យ និងកិច្ចប្រតិបត្តិការត្រួតពិនិត្យផ្ទៃក្នុងរបស់អង្គភាព ។

៣-ពិនិត្យឡើងវិញនូវភាពដែលជឿទុកចិត្តបាន ភាពទាន់ពេលវេលា និងភាពគ្រប់គ្រាន់នៃពត៌មានហិរញ្ញវត្ថុ និងកិច្ចប្រតិបត្តិការព្រមទាំងវិធីសាស្ត្រដែលប្រើប្រាស់ ដើម្បីកំណត់អត្តសញ្ញាណ វាស់វែង ធ្វើចំណាត់ថ្នាក់ និង រាយការណ៍អំពីពត៌មានទាំងនោះ ។

៤-ពិនិត្យឡើងវិញលើប្រព័ន្ធដែលបានបង្កើតរួច ដើម្បីធានាបាននូវភាពអនុលោម តាមគោលនយោបាយ ផែនការ នីតិវិធី ច្បាប់ និងបទបញ្ញាទាំងឡាយដែលមានឥទ្ធិពលសំខាន់លើកិច្ចប្រតិបត្តិការនិងការធ្វើរបាយការណ៍ព្រមទាំងការកំណត់អង្គភាពអោយអនុលោមតាមសំណូមពរនិងការកែលំអ ស្របតាមគោលនយោបាយរបស់អង្គភាព ។

៥-ពិនិត្យឡើងវិញលើមធ្យោបាយថែទាំការពារទ្រព្យសម្បត្តិ និងផ្ទៀងផ្ទាត់ទ្រព្យសម្បត្តិដែលមានឱ្យបានត្រឹមត្រូវ ។

៦-វាយតំលៃភាពសន្សំសំចៃនិងប្រសិទ្ធភាពពីការប្រើប្រាស់ធនធាន ផ្តល់ឱកាសកែលំអការអនុវត្តន៍កិច្ចប្រតិបត្តិការ និងផ្តល់អនុសាសន៍ដោះស្រាយរាល់បញ្ហាឱ្យបានសមរម្យ ។

៧-ពិនិត្យឡើងវិញលើកិច្ចប្រតិបត្តិការ កម្មវិធី និងគំរោងចំណាយមូលធន ដើម្បីធានាថា លទ្ធផលការងារ សមស្របតាមគោលបំណង និងគោលដៅដែលបានដាក់ចេញ តាមផែនការដែលបានកំណត់ ។

៨-ចូលរួមបង្កើតផែនការ គំនូសប្លង់ ការអភិវឌ្ឍន៍ ការអនុវត្តន៍ និងកិច្ចប្រតិបត្តិការ

លើប្រព័ន្ធមូលដ្ឋាន កុំព្យូទ័រសំខាន់ៗ ដើម្បីធានាថា :

ក- តម្រូវការរបស់អ្នកប្រើប្រាស់ត្រូវបានកំណត់ច្បាស់លាស់ ។

ខ- ការត្រួតពិនិត្យផ្ទៃក្នុងសមស្របត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ ។

គ- ប្រព័ន្ធសាកល្បងត្រូវបានប្រព្រឹត្តទៅក្នុងជំហានសមស្រប ។

ឃ- ប្រព័ន្ធឯកសារត្រូវបានធ្វើពេញលេញ និង មានភាពត្រឹមត្រូវ ។

៩-ពិនិត្យឡើងវិញលើនីតិវិធី និងការអនុវត្តន៍ ដើម្បីធានាថាវិធានការបានដាក់ចេញក្នុងគោលបំណង ការពារការកេងបន្លំ ។ ប្រសិនបើមានការកេងបន្លំកើតឡើង ប្រព័ន្ធនេះអាចទប់ស្កាត់បានទាន់ពេលវេលា ។

១០-ធ្វើសវនកម្មលើមជ្ឈមណ្ឌលសេវាកុំព្យូទ័រ តាមការិយបរិច្ឆេទ និងធ្វើការវាយតំលៃលើការកត់ត្រាបញ្ចូល ក្នុងប្រព័ន្ធដំណើរការទិន្នន័យសំខាន់ៗ ដើម្បីអោយប្រព័ន្ធទាំងនេះ អាចសំរេចតាមគោលបំណង និងគោលដៅ ព្រមទាំងធានាបានសុវត្ថិភាព សំរេចបានផលល្អ និងមានប្រសិទ្ធភាពខ្ពស់ ។

១១-ពិនិត្យឡើងវិញលើភាពអនុលោមតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាលស្តីពីសីលធម៌ ក្រមសីលធម៌ ចំពោះមន្ត្រីរាជការ ។

១២-ធ្វើរបាយការណ៍ផ្ញើជូនដល់ផ្នែកនីមួយៗរបស់ស្ថាប័ន ដែលទទួលបន្ទុកកែលំអ លើអនុសាសន៍ ។ សវនកម្មផ្ទៃក្នុង ត្រូវបញ្ជូនរាល់របាយការណ៍ទៅថ្នាក់ដឹកនាំអង្គភាពរបស់ខ្លួន និងផ្ញើជូនអាជ្ញាធរសវនកម្មជាតិ ។

១៣-សម្របសម្រួលយ៉ាងសកម្មការងារសវនកម្មផ្ទៃក្នុងជាមួយអាជ្ញាធរសវនកម្មជាតិ ។

១៤-ធ្វើរបាយការណ៍ប្រចាំត្រីមាសផ្ញើជូនថ្នាក់ដឹកនាំប្រតិបត្តិដែលទទួលខុសត្រូវ និងធ្វើរបាយការណ៍ប្រចាំ ឆមាស ផ្ញើជូនអាជ្ញាធរសវនកម្មជាតិដើម្បីជ្រាបអំពី :

ក- សកម្មភាពសមស្របដែលរកឃើញចំណុចសំខាន់ៗរបស់សវនកម្មផ្ទៃក្នុង

ខ-សកម្មភាពសវនកម្មត្រូវបានសំដៅផ្តោតលើ ហានិភ័យ និង បង្កើនភាពសន្សំសំចៃ ប្រសិទ្ធ ភាព និងភាព សំរេចផលល្អក្នុងកិច្ចប្រតិបត្តិការ ។

គ-សវនកម្មផ្ទៃក្នុងត្រូវធ្វើការសម្របសម្រួលរបាយការណ៍ជាមួយអាជ្ញាធរសវនកម្មជាតិ ដើម្បីជៀសវាង ការធ្វើសវនកម្មស្ទួនគ្នា ។

ឃ-ផែនការសវនកម្មផ្ទៃក្នុងត្រូវមានភាពសមស្រប ច្បាស់លាស់ គ្រប់គ្រាន់

ង-ការធ្វើរបាយការណ៍ផ្ញើជូនដល់ផ្នែកនីមួយៗរបស់ស្ថាប័ន ឬ ថ្នាក់ដឹកនាំដែលទទួលបន្ទុកសកម្មភាពកែលំអ អំពីលទ្ធផលសវនកម្មរកឃើញនូវចំណុចសំខាន់ៗមតិយោបល់ និងអនុសាសន៍របស់សវនករដែលបាន លើកឡើង ។

១៥-ផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំត្រូវដាក់ជូនថ្នាក់ដឹកនាំ ដើម្បីពិនិត្យ និងអនុម័តសំរេច ។

១៦-វាយតំលៃផែនការ ឬ សកម្មភាពស្តីពីស្ថានភាពនៃរបាយការណ៍កែលំអលើចំណុចរកឃើញរបស់សវនករ ។ ប្រសិនបើសកម្មភាពកែលំអនេះ ត្រូវបានពិចារណាថា ការកែលំអនេះ មិនមានលក្ខណៈសមស្របទេនោះ ត្រូវលើកយកមកពិភាក្សាបន្តដើម្បីអោយសំរេចបានតាមសំណូមពរដែលអាចទទួលយកបាន ។

១៧-ផ្តល់លទ្ធភាពសមស្របគ្រប់គ្រាន់ក្នុងការតាមដានដើម្បីធានាថា សកម្មភាពកែលំអត្រូវបានអនុវត្តដោយមានប្រសិទ្ធភាព។

**ប្រការ ៥** : មន្ត្រីអង្គភាពសវនកម្មផ្ទៃក្នុងដែលបានទទួលពត៌មានដោយផ្ទាល់ ឬដោយប្រយោល ក្នុងដំណើរការអនុវត្តន៍មុខនាទីរបស់ខ្លួន មិនត្រូវលាតត្រដាង ផ្សព្វផ្សាយ ឬនាំយកពត៌មានអោយទៅមជ្ឈដ្ឋានខាងក្រៅឡើយ លើកលែងតែករណីមានសេចក្តីត្រូវការចាំបាច់ក្នុងកិច្ចដំណើរការអនុវត្តន៍មុខនាទី និងភារកិច្ចនោះ ដែលតំរូវដោយបទប្បញ្ញត្តិផ្សេងៗទៀត ។

**ប្រការ ៦** : ឯករាជភាពនៃសវនកម្មផ្ទៃក្នុងមានៈ

- សវនករផ្ទៃក្នុងត្រូវឯករាជ្យលើសកម្មភាពសវនកម្មរបស់ខ្លួន ។ សវនករផ្ទៃក្នុងត្រូវមានឯករាជភាពក្នុងពេលបំពេញភារកិច្ចរបស់ខ្លួនដោយសេរី និងចំគោលដៅ ។ ឯករាជភាពនេះធ្វើអោយសវនករផ្ទៃក្នុងអាចផ្តល់ការវិនិច្ឆ័យយ៉ាងត្រឹមត្រូវ មិនស៊ីគ្រលំនិងមិនលំអៀងក្នុងការធ្វើសវនកម្ម ។ ឯករាជភាពអាចសំរេចទៅបាន តាមរយៈថ្នាក់ដឹកនាំរបស់អង្គភាពដែលមានស្មារតី មិនលំអៀង ។

- ប្រធានអង្គភាពសវនកម្មផ្ទៃក្នុងត្រូវទទួលខុសត្រូវលើមន្ត្រីម្នាក់ៗក្នុងអង្គភាព និងមានអំណាចគ្រប់គ្រាន់ក្នុងការចាត់តាំងដោយឯករាជ្យ ដើម្បីធានាបានទំហំការងារសវនកម្ម ត្រូវពិចារណាសមស្របគ្រប់គ្រាន់លើ របាយការណ៍សវនកម្ម និងអនុវត្តយ៉ាងត្រឹមត្រូវលើអនុសាសន៍សវនកម្ម ។

ប្រការ ៧ : ភាពមិនលំអៀងរបស់សវនករផ្ទៃក្នុង តម្រូវអោយអនុវត្តការងារសវនកម្ម ដោយមានជំនឿស្មោះត្រង់លើលទ្ធផលការងាររបស់ខ្លួន និងមិនត្រូវធ្វើការសម្របសម្រួលលើខ្លឹមសារសំខាន់ៗនៃរបាយការណ៍ទេ ។ សវនករផ្ទៃក្នុងមិនត្រូវស្ថិតនៅក្នុងស្ថានភាពដែលមានការបង្ខិតបង្ខំអោយធ្វើការវាយតំលៃផ្ទុយពីសុភវិនិច្ឆ័យ វិជ្ជាជីវៈជាសត្យានុម័តឡើយ ។ ស្ថានភាពណាដែលនឹងនាំមកនូវទំនាស់ផលប្រយោជន៍ជាក់ស្តែង និងភាពលំអៀង ត្រូវជៀសវាងដាច់ខាត នៅពេលដែលសវនករផ្ទៃក្នុងត្រូវបានតែងតាំងអោយបំពេញបេសសកម្មណាមួយ ។ ប្រធានសវនកម្មផ្ទៃក្នុងត្រូវទទួលយកពតិមានពីសវនករដែលទាក់ទង នឹងស្ថានភាព ដែលអាចនាំមកនូវទំនាស់ផលប្រយោជន៍ និងភាពលំអៀងក្នុងការវិនិច្ឆ័យ ។ ទន្ទឹមនេះសវនករត្រូវផ្តល់ពតិមាន មកប្រធានសវនកម្មផ្ទៃក្នុងវិញអំពីស្ថានការណ៍ទំនាស់ផលប្រយោជន៍របស់សវនករនោះ និងនាំមកនូវភាពលំអៀងដែលកំពុងមាន ឬ អាចកើតឡើងដោយហេតុផលណាមួយ ។

មិនអោយមានការបំពានលើការងាររបស់សវនករផ្ទៃក្នុង ចំពោះការទទួលខុសត្រូវក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួនទេ ។ នៅពេលសវនករផ្ទៃក្នុង ធ្វើសវនកម្មរាល់សកម្មភាពតាមសិទ្ធិអំណាច និងការទទួលខុសត្រូវដែលខ្លួនមាន និងត្រូវពង្រឹងដោយភាពមិនលំអៀង ។ លទ្ធផលការងារសវនកម្មផ្ទៃក្នុងត្រូវពិនិត្យឡើងវិញ មុនពេលធ្វើរបាយការណ៍សវនកម្មដែលពាក់ព័ន្ធ ដើម្បីផ្តល់ភាពសមហេតុផលថា ការងារនេះបានប្រព្រឹត្តិទៅចំគោលដៅ ។ ភាពមិនលំអៀងនៃសវនករផ្ទៃក្នុង គឺ មិនបំផ្លែងការពិតនិងមិនអនុគ្រោះ នៅពេលដែលសវនករផ្តល់អនុសាសន៍លើស្តង់ដារ ត្រួតពិនិត្យរាល់ប្រព័ន្ធ ឬ ពិនិត្យឡើងវិញរាល់នីតិវិធី មុនពេលអនុវត្តការងារ ។ ប្រព័ន្ធគូសប្លង់ ប្រព័ន្ធរៀបចំតំឡើង ប្រព័ន្ធកិច្ចប្រតិបត្តិការ និងសេចក្តីព្រាងនីតិវិធី លើរាល់ប្រព័ន្ធ មិនមែនជាមុខងារសវនកម្មទេ ។ ការប្រព្រឹត្តទៅសកម្មភាពទាំងនេះ គឺត្រូវធ្វើសវនកម្មពង្រឹងដោយមិនលំអៀង ។

ប្រការ ៨ : *__ភាពស្ទាត់ជំនាញនៃវិជ្ជាជីវៈ__* សវនកម្មផ្ទៃក្នុងត្រូវបំពេញការងាររបស់ខ្លួនដោយយកចិត្តទុកដាក់លើភាពស្ទាត់ជំនាញ និងវិជ្ជាជីវៈ ។ ភាពស្ទាត់ជំនាញនេះ គឺជាការទទួលខុសត្រូវរបស់សវនករផ្ទៃក្នុងម្នាក់ៗ និង អង្គភាពសវនកម្មផ្ទៃក្នុង ។ អង្គភាពសវនកម្មផ្ទៃក្នុងត្រូវជ្រើសរើសសវនករណាដែលមានចំណេះដឹងខ្ពស់ មានជំនាញ និងមានវិន័យ ដើម្បីធ្វើសវនកម្មអោយបានត្រឹមត្រូវ ។

*__ក-ការជ្រើសរើសបុគ្គលិក__*

អង្គភាពសវនកម្មផ្ទៃក្នុងត្រូវផ្តល់ការធានាបញ្ជាក់ថា សវនករផ្ទៃក្នុងត្រូវមានប្រវត្តិអប់រំ និង ជំនាញបច្ចេកទេសដើម្បីអនុវត្តការងារសវនកម្មឱ្យបានសមស្រប ។

ការធានាដ៏សមហេតុផល គឺ ត្រូវបានទទួលតាមរយៈលក្ខណៈសម្បត្តិនិងភាពស្ទាត់ជំនាញ របស់សវនករផ្ទៃក្នុង ។ ប្រធានអង្គភាពសវនកម្មផ្ទៃក្នុងត្រូវមានសុភវិនិច្ឆ័យត្រឹមត្រូវលើកំរិតអប់រំ បទពិសោធន៍ ការពិចារណា សមស្របលើវិសាលភាពការងារ និងកំរិតទទួលខុសត្រូវ ដើម្បីប្រគល់ តំណែងជាសវនកម្មផ្ទៃក្នុង ។

**ខ-ចំណេះដឹង កំរិតជំនាញ និងវិន័យ**

អង្គភាពសវនកម្មផ្ទៃក្នុងត្រូវមានចំណេះដឹង ជំនាញ និងវិន័យចាំបាច់ដើម្បីអនុវត្តការទទួល ខុសត្រូវ ក្នុងការធ្វើសវនកម្មរបស់ខ្លួន ។ សវនកម្មផ្ទៃក្នុងត្រូវប្រមូលផ្តុំមន្ត្រីមានចំណេះដឹង និងជំនាញ ចាំបាច់ ដើម្បីអនុវត្តវិជ្ជាជីវៈនៅក្នុងអង្គភាព ។ ចរិតពិសេសទាំងនេះរួមមាន ភាពស្ទាត់ជំនាញក្នុងការ អនុវត្តន៍រាល់ស្តង់ដារ នីតិវិធី និងបច្ចេកទេសសវនកម្មផ្ទៃក្នុង។

អង្គភាពសវនកម្មផ្ទៃក្នុងត្រូវមានអ្នកជំនួយការ ឬ ទីប្រឹក្សាដែលមានលក្ខណៈសម្បត្តិ ដូចជា ជំនាញគណនេយ្យ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ស្ថិតិ ដំណើរការទិន្នន័យអេឡិចត្រូនិច វិស្វកម្ម ពន្ធដារ និង ច្បាប់ ដែលត្រូវការចាំបាច់ដើម្បីសំរេចបានការទទួលខុសត្រូវលើសវនកម្ម ។ ទោះបីយ៉ាងណាមន្ត្រី ម្នាក់ៗរបស់អង្គភាព សវនកម្មផ្ទៃក្នុង មិនចាំបាច់មានលក្ខណៈសម្បត្តិដូចបានរៀបរាប់ខាងលើឡើយ ។

ដើម្បីអនុវត្តការងារសវនកម្មផ្ទៃក្នុង សវនករផ្ទៃក្នុងម្នាក់ៗត្រូវមានចំណេះដឹង និងជំនាញ ជាក់លាក់ ដូចខាងក្រោម :

- ភាពស្ទាត់ជំនាញក្នុងការអនុវត្តន៍រាល់ស្តង់ដារ នីតិវិធី និងបច្ចេកទេសសវនកម្មផ្ទៃក្នុង ។ ភាពស្ទាត់ជំនាញ គឺមានន័យថា សមត្ថភាពអនុវត្តចំណេះដឹងលើស្ថានភាពដែលបានជួបប្រទះនិងដោះ ស្រាយស្ថានភាព ទាំងនោះ ដោយមិនចាំបាច់ធ្វើការទៅតាមការស្រាវជ្រាវ និងជំនួយបច្ចេកទេស ។

- ភាពស្ទាត់ជំនាញនៅក្នុងគោលការណ៍គណនេយ្យ និងបច្ចេកទេស គឺតំរូវអោយសវនករ ធ្វើ ការងារលើបញ្ជីការ និងរបាយការណ៍ហិរញ្ញវត្ថុ ។

- ការយល់ដឹងអំពីគោលការណ៍គ្រប់គ្រងបានតំរូវអោយទទួលស្គាល់ និងវាយតំលៃលើភាពប៉ះ ពាល់ ព្រមទាំងចំណុចសំខាន់ៗនៃគម្លាតពីកិច្ចប្រតិបត្តិការអាជីវកម្មដែលល្អប្រសើរ ។ ការយល់ដឹង មានន័យថា សមត្ថភាពអនុវត្តចំណេះដឹងដ៏ទូលំទូលាយលើស្ថានភាពដែលបានជួបប្រទះ ការទទួល ស្គាល់ចំណុចគម្លាតសំខាន់ៗទាំងនោះ និងលទ្ធភាពអនុវត្តស្រាវជ្រាវចាំបាច់ ដើម្បីសំរេចបានដំណោះ ស្រាយសមហេតុផលមួយ ។

- ការវាយតំលៃ គឺ ជាតំរូវការមូលដ្ឋានគ្រឹះលើមុខជំនាញ ដូចជាគណនេយ្យ ពន្ធដារ សេដ្ឋកិច្ច ច្បាប់ពាណិជ្ជកម្ម ហិរញ្ញវត្ថុ បរិមាណវិធី និងប្រព័ន្ធពត៌មានវិទ្យា ។ការវាយតំលៃមានន័យថាសមត្ថភាពទទួលស្គាល់បញ្ហាដែលកំពុងកើតមាន ឬ បញ្ហាជាសក្តានុពល និងកំណត់បន្ថែមលើការស្រាវជ្រាវ ដើម្បីរ៉ាប់រង ឬ ជាជំនួយដែលអាចទទួលយកបាន ។

### ឥ-ការពិនិត្យតាមដាន

អង្គភាពសវនកម្មផ្ទៃក្នុងត្រូវផ្តល់ការធានាថា សវនកម្មផ្ទៃក្នុងត្រូវបានពិនិត្យតាមដានយ៉ាងត្រឹមត្រូវ ។ ប្រធានសវនកម្មផ្ទៃក្នុងទទួលខុសត្រូវក្នុងការពិនិត្យតាមដានការងារសវនកម្មឱ្យបាន សមស្រប ។ ការពិនិត្យតាមដាន គឺជាដំណើរការបន្តបន្ទាប់ ដោយចាប់ផ្តើមពីផែនការនិងបញ្ចប់ដោយផ្តល់សេចក្តីសន្និដ្ឋានលើការងារសវនកម្ម។

ការពិនិត្យតាមដានរួមមាន :

- ផ្តល់នូវសេចក្តីណែនាំសមស្របដល់មន្ត្រីក្រោមឱវាទ នៅពេលចាប់ផ្តើមធ្វើសវនកម្ម និងអនុម័តលើ កម្មវិធីសវនកម្ម ។

- ពិនិត្យមើលកម្មវិធីសវនកម្មដែលបានអនុម័ត និងអនុវត្តរួច លើកលែងតែគម្លាត ពីយុត្តិកម្ម និង សិទ្ធិអនុញ្ញាត។

- បង្ហាញថា ឯកសារការងារសវនកម្មមានគ្រប់គ្រាន់ ដើម្បីគាំទ្រនូវចំណុចរកឃើញសំខាន់ៗ សេចក្តីសន្និដ្ឋាន និង របាយការណ៍ ។

- ធានាថារបាយការណ៍សវនកម្មមានលក្ខណៈត្រឹមត្រូវ ចំគោលដៅច្បាស់លាស់ សង្ខេបមានប្រយោជន៍ និងទាន់ពេលវេលា ។

- បង្ហាញថា គោលដៅនៃសវនកម្មត្រូវបានសំរេច ។

ភស្តុតាងត្រឹមត្រូវនៃការពិនិត្យតាមដានត្រូវមានឯកសារតំកល់ទុក ។ វិសាលភាពនៃការពិនិត្យតាមដាន តំរូវអោយផ្អែកតាមភាពស្ទាត់ជំនាញរបស់សវនករផ្ទៃក្នុង និងភាពលំបាកស្មុគស្មាញនៃការងារសវនកម្មនោះ ។ ប្រធានសវនកម្មផ្ទៃក្នុងត្រូវទទួលខុសត្រូវលើរាល់ការងារ សវនកម្មដែលបានប្រព្រឹត្តទៅដោយអង្គភាពរបស់ខ្លួន។

**ប្រការ ៩** : សវនករផ្ទៃក្នុងត្រូវអនុលោមតាមស្តង់ដារវិជ្ជាជីវៈ ។ ក្រមសីលធម៌នេះ តំរូវអោយមានស្តង់ដារខ្ពស់ប្រកបដោយភាពទៀងត្រង់ មិនលំអៀង យកចិត្តទុកដាក់ និងស្មោះត្រង់ ដែលសវនករផ្ទៃក្នុងត្រូវអនុលោមតាម ។ សវនករផ្ទៃក្នុងត្រូវតែអនុលោមតាមគោលការណ៍ណែនាំ

សេចក្តីថ្លែង អំពីឥរិយាបថ និងក្រមសីលធម៌នានាទៀត ដែលប្រកាសអោយប្រើដោយរាជរដ្ឋាភិបាល ចំពោះមន្ត្រីបុគ្គលិកបំរើការងារសាធារណៈ ។

**ប្រការ ១០** : ធនធានមនុស្ស និងទំនាក់ទំនងទៅនិងការងារសវនកម្មផ្ទៃក្នុងត្រូវមានជំនាញ ដូចខាងក្រោម :

- សវនករផ្ទៃក្នុងត្រូវមានជំនាញក្នុងការធ្វើទំនាក់ទំនងជាមួយពលរដ្ឋយ៉ាងមានប្រសិទ្ធភាព ។ សវនករផ្ទៃក្នុង ត្រូវយល់ច្បាស់អំពីការងារទំនាក់ទំនង និងរក្សាទំនាក់ទំនងល្អជាមួយអង្គភាព ដែលត្រូវធ្វើសវនកម្ម ។
- សវនករផ្ទៃក្នុងត្រូវមានជំនាញក្នុងការធ្វើទំនាក់ទំនងផ្ទាល់មាត់ និងលាយលក្ខអក្សរ ដូច្នេះ សវនករផ្ទៃក្នុង នាំមកកាន់តែច្បាស់ និងសំរេចផលល្អនូវបញ្ហាដែលទាក់ទង នឹងគោលដៅ ការវាយតំលៃ សេចក្តីសន្និដ្ឋាន និងអនុសាសន៍សវនកម្ម ។

**ប្រការ ១១** : ***ការសិក្សាអប់រំ*** : សវនករផ្ទៃក្នុងត្រូវបង្កើនសមត្ថភាពបច្ចេកទេសរបស់ខ្លួនតាមរយៈការសិក្សាអប់រំបន្ត ដើម្បីរក្សាភាពស្ទាត់ជំនាញរបស់ខ្លួន ។ សវនករផ្ទៃក្នុងត្រូវរាយការណ៍ជាប្រចាំអំពីការរីកចំរើននិងការអភិវឌ្ឍន៍ស្តង់ដារ នីតិវិធី និងបច្ចេកទេសសវនកម្មផ្ទៃក្នុង ។ ការសិក្សាអប់រំបន្តអាចធ្វើទៅបានតាមរយៈចូលជាសមាជិក និង ចូលរួមក្នុងសង្គមវិជ្ជាជីវៈ មហាសន្និបាត សិក្ខាសាលា វគ្គបំពាក់បំប៉ន កម្មវិធីបំពាក់បំប៉ន និងការស្រាវជ្រាវគំរោងជាដើម ។

**ប្រការ ១២** : ការយកចិត្តទុកដាក់លើវិជ្ជាជីវៈរបស់សវនករគឺ :

- ត្រូវមានការយកចិត្តទុកដាក់លើវិជ្ជាជីវៈក្នុងការអនុវត្តន៍សវនកម្មផ្ទៃក្នុង ។ ការយកចិត្តទុកដាក់នេះ ទាមទារអោយអនុវត្តដោយមានការប្រុងប្រយ័ត្ន ដោយសង្ឃឹមថា សវនករផ្ទៃក្នុងនឹងមានសមត្ថភាពជំនាញសមស្របប្រហាក់ប្រហែលគ្នា ។ ដូច្នេះការយកចិត្តទុកដាក់លើវិជ្ជាជីវៈត្រូវសមស្របជាមួយភាពស្មុគស្មាញនៃសវនកម្មដែលកំពុងធ្វើ ។ ក្នុងការអនុវត្តន៍ជាក់ស្តែង ការយកចិត្តទុកដាក់លើវិជ្ជាជីវៈ សវនករផ្ទៃក្នុង ត្រូវវាងវៃលើភាពដែលអាចកើតមានឡើងនូវកំហុសឆ្គង ភាពភាន់ច្រឡំ ភាពភ្លេចភ្លាំង គ្មានប្រសិទ្ធភាព ខ្ជះខ្ជាយ ភាពមិនសំរេចផល និងទំនាស់ផលប្រយោជន៍ ។

សវនករផ្ទៃក្នុង ត្រូវមានភាពវាងវៃ ដោះស្រាយរាល់ស្ថានភាពទាំងនោះ និងសកម្មភាពដែលមានភាពមិនប្រក្រតី ។

-ត្រូវកំណត់បញ្ជាក់លើការត្រួតពិនិត្យ និងការផ្តល់អនុសាសន៍កែលំអភាពមិនគ្រប់គ្រាន់ដើម្បីជំរុញអោយអនុលោមតាមនីតិវិធី និងការអនុវត្តន៍ដែលអាចទទួលយកបាន ។

-ត្រូវយកចិត្តទុកដាក់បញ្ជាក់នូវភាពប្រុងប្រយ័ត្ន និងសមត្ថភាពសមហេតុផល មិនមែនជាការប្រព្រឹត្តទៅដោយគ្មានកំហុសនោះទេ ។ ការប្រុងប្រយ័ត្នត្រូវអោយសវនករធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់កំរិតភាពសមហេតុផលណាមួយ ប៉ុន្តែមិនតំរូវឱ្យលំអិតការងារសវនកម្មលើរាល់ប្រតិបត្តិការសេដ្ឋកិច្ចទេ ។ ហេតុដូចនេះ សវនករផ្ទៃក្នុង មិនធានាដាច់ខាតលើភាពមិនអនុលោមតាម និងភាពមិនប្រក្រតីដែលថា មិនអាចកើតមានឡើងនោះទេ ។ ទោះបីយ៉ាងណាក៏ដោយ ភាពមិនប្រក្រតីដែលអាចកើតមានឡើង និងភាពដែលមិនអនុលោមតាម ត្រូវពិចារណាពេលណាដែលសវនករផ្ទៃក្នុងអនុវត្តការងារ ។

-ក្នុងករណីដែលមានការសង្ស័យលើកំហុសធ្ងន់ធ្ងរនោះ សវនករផ្ទៃក្នុងត្រូវជូនដំណឹងដល់ថ្នាក់ដឹកនាំនៃអង្គភាពឱ្យបានជ្រាប ។ សវនករផ្ទៃក្នុងអាចផ្តល់យោបល់អោយធ្វើការស៊ើបអង្កេតនៅក្នុងករណីចាំបាច់ ។ បន្ទាប់មកសវនករផ្ទៃក្នុងត្រូវតាមដានមើលការទទួលខុសត្រូវរបស់អង្គភាពសវនកម្មផ្ទៃក្នុង អំពីការផ្តល់យោបល់នោះ ។

-ត្រូវអនុវត្តការយកចិត្តទុកដាក់លើវិជ្ជាជីវៈ មានន័យថា ការប្រើប្រាស់ជំនាញ និងសុភវិនិច្ឆ័យសវនកម្ម សមហេតុផលក្នុងការបំពេញការងារសវនកម្ម ។ គោលដៅចុងក្រោយនេះ សវនករផ្ទៃក្នុងត្រូវពិចារណាដូចខាងក្រោម :

-វិសាលភាពនៃការងារសវនកម្មត្រូវតែសំរេចតាមគោលដៅសវនកម្ម

-ភាពប៉ះពាល់ ឬ ចំណុចសំខាន់ៗ ពាក់ព័ន្ធលើរាល់នីតិវិធីសវនកម្មដែលបានអនុវត្ត

-ភាពសមស្រប និងភាពសំរេចផលល្អនៃការត្រួតពិនិត្យផ្ទៃក្នុង

-តំលៃសវនកម្មទាក់ទងជាមួយនឹងផលប្រយោជន៍ដែលនឹងទទួលបាន

-ត្រូវយកចិត្តទុកដាក់លើវិជ្ជាជីវៈរួមមាន ការវាយតំលៃលើស្តង់ដារនៃកិច្ចប្រតិបត្តិការដែលបានបង្កើតឡើង និងការកំណត់ថា ស្តង់ដារទាំងនោះអាចទទួលយក និងអាចអនុវត្តបាន ។ នៅពេលដែលស្តង់ដារ មានភាពមិនច្បាស់លាស់ ការបកស្រាយពន្យល់ស្តង់ដារដែលយកជាបាទការនោះ នឹងត្រូវធ្វើការស្រាវជ្រាវបន្ថែម ។ ប្រសិនបើ សវនករផ្ទៃក្នុងបានតំរូវអោយធ្វើការបកស្រាយ ឬ

ជ្រើសរើសស្តង់ដារនៃកិច្ចប្រតិបត្តិការ សវនករផ្ទៃក្នុងត្រូវព្រមព្រៀងស្រាវជ្រាវជាមួយអង្គភាព ដែលត្រូវបានធ្វើសវនកម្មទាក់ទងអំពីស្តង់ដារចាំបាច់ ដើម្បីវាស់វែងការប្រព្រឹត្តិទៅនៃកិច្ចប្រតិបត្តិការ ។

ប្រការ ១៣ : ***ទំហំនៃការងារសវនកម្មផ្ទៃក្នុង*** រួមមាន ការពិនិត្យ និងការវាយតំលៃលើភាពសមស្រប គ្រប់គ្រាន់ ភាពសំរេចផលល្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់អង្គភាព ព្រមទាំងគុណភាពនៃការប្រព្រឹត្តទៅក្នុងការអនុវត្តន៍ ភារកិច្ចទទួលខុសត្រូវ ។

គោលបំណងនៃការពិនិត្យឡើងវិញលើភាពគ្រប់គ្រាន់លើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង គឺដើម្បីអះអាងថា ប្រព័ន្ធដែលបានបង្កើតឡើង ផ្តល់នូវភាពសមហេតុផល ធានាថា គោលបំណង និងគោលដៅរបស់អង្គភាព នឹងត្រូវសំរេចបាននូវប្រសិទ្ធភាព និងសន្សំសំចៃ ។

គោលបំណងនៃការពិនិត្យឡើងវិញលើភាពសំរេចផលល្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង គឺដើម្បីធានាអះអាងថា ប្រព័ន្ធនេះត្រឹមត្រូវតាមមុខងារដែលចង់បាន ។

គោលបំណងនៃការពិនិត្យឡើងវិញលើគុណភាពនៃការប្រព្រឹត្តិទៅ គឺដើម្បីធានាអះអាងថា គោលបំណង និងគោលដៅរបស់អង្គភាពត្រូវបានសំរេច ។

គោលបំណងចំបងរបស់ការត្រួតពិនិត្យផ្ទៃក្នុង គឺដើម្បីធានាថា :

- ពត៌មានដែលជឿទុកចិត្តបាន និង ពេញលេញត្រឹមត្រូវ
- ភាពអនុលោមតាមគោលនយោបាយ ផែនការ នីតិវិធី ច្បាប់ និងបទបញ្ជា
- ការការពារថែទាំទ្រព្យសម្បត្តិរបស់អង្គភាព
- ការប្រើប្រាស់ធនធានមានលក្ខណៈសន្សំសំចៃ និងប្រសិទ្ធភាព
- ការសំរេចបាននូវគោលបំណង និងគោលដៅដែលបានបង្កើតសំរាប់កិច្ចប្រតិបត្តិការ និងកម្មវិធី ។

### - ពត៌មានដែលជឿទុកចិត្តបាន និង ពេញលេញត្រឹមត្រូវ

សវនករផ្ទៃក្នុងត្រូវពិនិត្យឡើងវិញនូវភាពជឿទុកចិត្តបាន ភាពពេញលេញត្រឹមត្រូវលើពត៌មានហិរញ្ញវត្ថុ និងកិច្ចប្រតិបត្តិការ និងមធ្យោបាយ ដែលត្រូវបានប្រើប្រាស់ ដើម្បីកំណត់អត្តសញ្ញាណ វាស់វែង ចំណាត់ថ្នាក់ និងរាយការណ៍ពត៌មានទាំងនោះ ។

ប្រព័ន្ធពត៌មានផ្តល់ទិន្នន័យសំរាប់ធ្វើការសំរេចអនុម័តត្រួតពិនិត្យ និង អនុលោមតាមតំរូវការខាងក្រៅ ។ ដូច្នេះសវនករផ្ទៃក្នុងត្រូវពិនិត្យប្រព័ន្ធពត៌មាន និងភាពសមស្របគ្រប់គ្រាន់ ដើម្បីអះអាងថា :

- បញ្ជីការ របាយការណ៍ហិរញ្ញវត្ថុ និងកិច្ចប្រតិបត្តិការដែលមានពត៌មានត្រឹមត្រូវ អាចជឿទុកចិត្តបានទាន់ពេលវេលា ពេញលេញ និងមានអត្ថប្រយោជន៍ ។

- ត្រួតពិនិត្យលើបញ្ជីការកត់ត្រា និងរបាយការណ៍ដែលមានលក្ខណៈសមស្រប គ្រប់គ្រាន់ ដោយសំរេចបានផលល្អ ។

- ***ភាពអនុលោមតាមគោលនយោបាយ ផែនការ នីតិវិធី ច្បាប់ និងបទបញ្ជា***

សវនករផ្ទៃក្នុងត្រូវពិនិត្យឡើងវិញរាល់ប្រព័ន្ធដែលបានបង្កើតឡើង ដើម្បីធានាបានភាពអនុលោមតាមគោលនយោបាយ ផែនការ នីតិវិធី ច្បាប់ និងបទបញ្ជា ដែលអាចមានឥទ្ធិពល យ៉ាងខ្លាំងលើកិច្ចប្រតិបត្តិការ របាយការណ៍ និងត្រូវកំណត់ភាពអនុលោមតាមរបស់អង្គភាព ។

ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ត្រូវទទួលខុសត្រូវលើការបង្កើតប្រព័ន្ធ ដើម្បីធានាបានភាពអនុលោមតាមតំរូវការរាល់គោលនយោបាយ ផែនការ នីតិវិធី ច្បាប់ និងបទបញ្ជា ដែលមានជាធរមាន ។ សវនករផ្ទៃក្នុង ត្រូវទទួលខុសត្រូវលើការកំណត់ប្រព័ន្ធអោយមានភាពសមស្រប និងសំរេចផលល្អ ហើយត្រូវកំណត់រាល់សកម្មភាពសវនកម្មដែលកំពុងអនុលោមតាមតំរូវការសមស្របនោះ ។

- ***ការការពារថែទាំទ្រព្យសម្បត្តិ***

សវនករផ្ទៃក្នុងត្រូវពិនិត្យឡើងវិញនូវវិធានការការពារថែទាំទ្រព្យសម្បត្តិអោយបានសមស្របនិងពិនិត្យបញ្ជាក់ រាល់ទ្រព្យសម្បត្តិដែលមាន ។ សវនករផ្ទៃក្នុងត្រូវពិនិត្យឡើងវិញលើមធ្យោបាយប្រើប្រាស់ការពារថែទាំ ទ្រព្យសម្បត្តិគ្រប់ប្រភេទដែលបានបាត់បង់ ដូចជាផលបាត់បង់ពីចោរលួច អគ្គិភ័យ សកម្មភាពមិនស្របច្បាប់ ឬ មិនត្រឹមត្រូវ និងអាកាសធាតុ ។ ពេលផ្ទៀងផ្ទាត់ទ្រព្យសម្បត្តិ សវនករផ្ទៃក្នុងត្រូវប្រើប្រាស់រាល់នីតិវិធី អោយបានសមស្រប ។

- ***ការប្រើប្រាស់ធនធានមានលក្ខណៈសន្សំសំចៃ និង ប្រសិទ្ធភាព***

សវនករផ្ទៃក្នុងត្រូវវាយតំលៃលើភាពសន្សំសំចៃនិងប្រសិទ្ធភាពនៃធនធានដែលបានប្រើប្រាស់។ ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ត្រូវទទួលខុសត្រូវចំពោះការដាក់អោយប្រើប្រាស់រាល់ស្តង់ដារកិច្ចប្រតិបត្តិការ ដើម្បីវាស់វែងសកម្មភាពប្រើប្រាស់ធនធានដែលមានលក្ខណៈសន្សំសំចៃ និងប្រសិទ្ធភាព ។ សវនករផ្ទៃក្នុង ត្រូវទទួលខុសត្រូវ ក្នុងការកំណត់ដូចតទៅ :

- ស្តង់ដារកិច្ចប្រតិបត្តិការដែលបានបង្កើតឡើងសំរាប់វាស់វែងភាពសន្សំសំចៃ និង ប្រសិទ្ធភាព

- ស្តង់ដារកិច្ចប្រតិបត្តិការដែលបានបង្កើតឡើងអាចយល់បាន និងអនុវត្តបាន

- គម្លាតពីស្តង់ដារកិច្ចប្រតិបត្តិការត្រូវបានកំណត់សំគាល់ វិភាគ និងរាយការណ៍ជូនថ្នាក់ដឹកនាំទទួលបន្ទុកអនុវត្តកែលំអ

- ត្រូវជំរុញអោយអនុវត្តបានរាល់សកម្មភាពកែលំអ

រាល់សវនកម្មពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានដែលមានលក្ខណៈសន្សំសំចៃ និងមានប្រសិទ្ធភាពត្រូវតែកំណត់លក្ខខ័ណ្ឌដូចខាងក្រោមៈ

- ប្រើប្រាស់មិនអស់លទ្ធភាពនៃឧបករណ៍សំភារៈ
- ការងារគ្មានផលិតភាព
- នីតិវិធីដែលប្រើប្រាស់គ្មានតំលៃត្រឹមត្រូវ
- ចំនួនបុគ្គលិកលើស ឬ ខ្វះ ។

- ***<u>ការសំរេចបានគោលបំណង និងគោលដៅដែលបានបង្កើតសំរាប់កិច្ចប្រតិបត្តិការ និងកម្មវិធី</u>***

សវនករផ្ទៃក្នុងត្រូវពិនិត្យឡើងវិញរាល់កិច្ចប្រតិបត្តិការ ឬ កម្មវិធី ដើម្បីបញ្ជាក់អះអាងថា លទ្ធផលស្របទៅតាមគោលបំណង គោលដៅដែលបានបង្កើតឡើង រាល់កិច្ចប្រតិបត្តិការ និងកម្មវិធីត្រូវបានអនុវត្តតាមផែនការកំណត់ ។

ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ទទួលខុសត្រូវលើការបង្កើតគោលបំណង និងគោលដៅទាំងឡាយនៃកិច្ចប្រតិបត្តិការ ឬ កម្មវិធី ការបង្កើតនិងការអនុវត្តន៍រាល់នីតិវិធីត្រួតពិនិត្យ និងសំរេចបានលទ្ធផលតាមកម្មវិធី ឬ កិច្ចប្រតិបត្តិការដែលចង់បាន ។ សវនករផ្ទៃក្នុងត្រូវបញ្ជាក់អះអាងថា រាល់គោលបំណង និង គោលដៅត្រូវបានអនុលោមតាមបទប្បញ្ញត្តិរបស់អង្គភាព និងអនុវត្តសំរេចបាន ។

សវនករផ្ទៃក្នុងត្រូវជួយផ្តល់ដល់អ្នកគ្រប់គ្រងដែលបានបង្កើតគោលបំណង គោលដៅ និងប្រព័ន្ធ ដើម្បីកំណត់ថា ការសន្មត់ទាំងឡាយអោយបានសមស្របពត៌មានដែលពាក់ព័ន្ធត្រូវបានកំពុងប្រើប្រាស់ត្រឹមត្រូវ ការត្រួតពិនិត្យដ៏សមរម្យ ត្រូវដាក់បញ្ចូលក្នុងកិច្ចប្រតិបត្តិការ និងកម្មវិធី ។

**ប្រការ ១៤** : ការប្រព្រឹត្តទៅនៃការងារសវនកម្មរួមមាន ការបង្កើតផែនការសវនកម្ម ការពិនិត្យ និងការវាយតំលៃលើពត៌មាន ការរាយការណ៍លទ្ធផល និងការតាមដាន ។ សវនករផ្ទៃក្នុងត្រូវទទួល

ខុសត្រូវរៀបចំផែនការ និងការអនុវត្តន៍កិច្ចការសវនកម្មដែលជាកម្មវត្ថុនៃការពិនិត្យតាមដានឡើងវិញ និងអនុម័ត ។

- ***ការបង្កើតផែនការសវនកម្ម***

ការបង្កើតផែនការត្រូវមានឯកសារដូចខាងក្រោម :

- ការបង្កើតគោលបំណងសវនកម្ម និងទំហំការងារសវនកម្ម
- ការទទួលយកប្រវត្តិពត៌មានអំពីសកម្មភាពដែលត្រូវធ្វើសវនកម្ម
- ការកំណត់ធនធានចាំបាច់ដើម្បីធ្វើសវនកម្ម
- ការរាយការណ៍ជូនថ្នាក់ដឹកនាំណាដែលត្រូវការចង់ដឹងពីសវនកម្ម
- ការអនុវត្តន៍អោយបានសមស្របលើការស្ទង់មតិស្វែងយល់អំពីរាល់សកម្មភាព និងការត្រួតពិនិត្យដែលត្រូវធ្វើសវនកម្មតាមទីកន្លែង ដើម្បីកំណត់បណ្តាផ្នែកដែលសង្កត់ធ្ងន់ ក្នុងការធ្វើសវនកម្ម ព្រមទាំងអញ្ជើញអង្គភាព ដែលបានធ្វើសវនកម្មមកធ្វើការបកស្រាយ និងសំណូមពរ
- ការសរសេរជាលាយលក្ខអក្សរនៃកម្មវិធីសវនកម្ម
- ការកំណត់ការរាយការណ៍ជូនថ្នាក់ដឹកនាំណា នៅពេលណា និងយ៉ាងដូចម្តេច អំពីលទ្ធផលសវនកម្ម
- ការទទួលយកអនុម័តលើផែនការការងារសវនកម្ម ។

- ***ការពិនិត្យ និង ការវាយតំលៃលើពត៌មាន***

សវនករផ្ទៃក្នុងត្រូវប្រមូលឯកសារវិភាគ និង បកស្រាយពត៌មានដើម្បីជាជំនួយដល់លទ្ធផលសវនកម្ម ។ ដំណើរការពិនិត្យ និងវាយតំលៃពត៌មាន រួមមានដូចខាងក្រោមៈ

-ពត៌មានត្រូវបានប្រមូលលើគ្រប់បញ្ហាដែលពាក់ព័ន្ធនឹងគោលបំណងសវនកម្ម និងទំហំនៃការងារសវនកម្ម ។

-ពត៌មានត្រូវតែមានភាពគ្រប់គ្រាន់ ភាពពេញលេញ ប្រទាក់ក្រឡាគ្នា និងអត្ថប្រយោជន៍ ដើម្បីផ្តល់មូលដ្ឋានល្អសំរាប់រាល់ចំណុចរកឃើញសវនកម្ម និងអនុសាសន៍សវនកម្ម ។

ពត៌មានដែលមានភាពគ្រប់គ្រាន់ គឺ ជាពត៌មានពិតប្រាកដ សមស្រប និងអាចជឿទុកចិត្តបាន។ ដូច្នេះ ទើបថ្នាក់ដឹកនាំសំខាន់ៗ ដែលទទួលរបាយការណ៍ អាចយល់ព្រមទទួលយកសេចក្តីសន្និដ្ឋានរបស់សវនករ ។

ពត៌មានដែលមានភាពពេញលេញ គឺ ពត៌មានដែលអាចជឿបាន និងអាចជាមូលដ្ឋានសំរាប់ការសំរេចអោយបានយ៉ាងប្រសើរ ។

ពត៌មានដែលប្រទាក់ក្រឡាគ្នា គឺជាពត៌មានដែលនាំទៅដល់ការរកឃើញខុសត្រូវ និងនាំអោយអាចធ្វើដល់ចំណុចរកឃើញ ដែលពាក់ព័ន្ធរាល់គោលបំណងសវនកម្ម ។

ពត៌មានដែលមានអត្ថប្រយោជន៍ គឺ ជាពត៌មាន ដែលជួយដល់អង្គភាពសំរេចបានគោលដៅរបស់ខ្លួន ។

នីតិវិធីសវនកម្មរួមមាន ការប្រើបច្ចេកទេសធ្វើតេស្ត និង តាងគំរូដែលត្រូវបានជ្រើសរើសទុកមុនគ្រប់កន្លែងអនុវត្ត និងពង្រីកទំហំ ឬជ្រើសរើស ក្នុងករណីដែលអាចធ្វើបាន ។

ដំណើរការប្រមូលឯកសារ ការវិភាគ និងការបកស្រាយពត៌មាន ត្រូវបានពិនិត្យតាមដានដើម្បីផ្តល់ការធានាសមស្របថា សវនករគ្មានភាពលំអៀង និងសំរេចបានគោលដៅ ។

ឯកសារការងារសវនកម្មត្រូវរៀបចំដោយសវនករ និងត្រូវពិនិត្យឡើងវិញដោយគណៈគ្រប់គ្រងរបស់អង្គភាពសវនកម្មផ្ទៃក្នុង ។ ឯកសារទាំងនេះ ត្រូវកត់ត្រាទុកអំពីពត៌មានដែលបានទទួលយក និងបានវិភាគហើយ ដើម្បីជាជំនួយមូលដ្ឋានសំរាប់រាល់ចំណុចរកឃើញ និងអនុសាសន៍ដែលត្រូវរាយការណ៍ ។

- ***ការរាយការណ៍លទ្ធផល***

សវនករផ្ទៃក្នុងត្រូវរាយការណ៍អំពីលទ្ធផលការងារសវនកម្មរបស់ខ្លួន ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ របាយការណ៍ ដែលបានរៀបចំជាលាយលក្ខអក្សរ ត្រូវបានប្រកាសផ្សាយបន្ទាប់ពីការធ្វើសវនកម្មបានបញ្ចប់ជាស្ថាពរ ។ របាយការណ៍បណ្តោះអាសន្ន ដែលជាលាយលក្ខអក្សរក្តី ឬ ផ្ទាល់មាត់ក្តី អាចជាផ្លូវការក៏បាន ឬ មិនផ្លូវការក៏បាន ។

សវនករផ្ទៃក្នុងត្រូវពិភាក្សារាល់សេចក្តីសន្និដ្ឋាន និងអនុសាសន៍ជាមួយថ្នាក់ដឹកនាំក្រសួងស្ថាប័ន និង សហគ្រាសសាធារណៈដែលមានកំរិតសមស្រប មុនពេលប្រកាសផ្សាយរបាយការណ៍ជាលាយលក្ខអក្សរចុងក្រោយ ។

របាយការណ៍ត្រូវតែចំគោលដៅច្បាស់លាស់ មិនបំផ្លើស មិនប្រឌិត និងទាន់ពេលវេលា ។

របាយការណ៍ត្រូវបានបង្ហាញតាមគោលបំណង ទំហំខ្លឹមសារ និងលទ្ធផលសវនកម្មសមស្របត្រឹមត្រូវព្រមទាំងត្រូវមានមតិយោបល់របស់សវនករ ។

របាយការណ៍ត្រូវរួមមានអនុសាសន៍សំរាប់កែលំអ ការអនុវត្តន៍ចំណេះដឹងដ៏ល្អប្រសើរ និងការអនុវត្តន៍ឱ្យបានត្រឹមត្រូវនាពេលអនាគត ។

ត្រូវបញ្ចូលទស្សនៈយោបល់របស់អង្គភាពដែលបានធ្វើសវនកម្មទៅ ក្នុងសេចក្តីសន្និដ្ឋាននិងអនុសាសន៍ នៃរបាយការណ៍សវនកម្ម ។

ប្រធានអង្គភាពសវនកម្មផ្ទៃក្នុង ឬ អ្នករៀបចំគំរោង ត្រូវពិនិត្យឡើងវិញ និងអនុម័តលើ របាយការណ៍ សវនកម្មចុងក្រោយ មុនប្រកាសផ្សាយព្រមទាំងសំរេចផ្ញើជូនរបាយការណ៍ទៅថ្នាក់ដឹកនាំ ។

- ***ការតាមដាន***

សវនករផ្ទៃក្នុងត្រូវតាមដានដើម្បីធានាអះអាងថា ការរាយការណ៍ចំណុចរកឃើញសវនកម្ម ត្រូវបានកែលំអសមស្របត្រឹមត្រូវ ។ សវនករផ្ទៃក្នុងត្រូវកំណត់ការអនុវត្តន៍កែលំអដើម្បីសំរេច

លទ្ធផលដែលចង់បាន ។ ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ឬ ក្រុមប្រឹក្សាភិបាល ត្រូវសន្មត់ហានិភ័យលើការអនុវត្តន៍ណាដែលមិនអាចធ្វើទៅបានក្នុងចំណុចរកឃើញដែលមានចែងក្នុងរបាយការណ៍ ។

**ប្រការ ១៥** : ត្រូវបានហាមឃាត់ដាច់ខាតនូវរាល់សកម្មភាពរារាំងចំពោះការចាត់តាំងមន្ត្រី និងសិទ្ធិអំណាចរបស់អង្គភាពសវនកម្មផ្ទៃក្នុង និងហាមការរារាំង ឬ ពន្យាពេលរបស់សវនករផ្ទៃក្នុងចូលធ្វើសវនកម្ម លើរាល់សកម្មភាព រាល់បញ្ជីទ្រព្យសម្បត្តិ និងបុគ្គលិករបស់អង្គភាព ។

ប្រសិនបើជួបប្រទះសកម្មភាពរារាំង ឬ ពន្យាពេលធ្វើសវនកម្ម អង្គភាពសវនកម្មផ្ទៃក្នុង មានសិទ្ធិធ្វើរបាយការណ៍សំណូមពរជូនទៅអាជ្ញាធរសវនកម្មជាតិ ដើម្បីធ្វើអន្តរាគមន៍ឱ្យកិច្ចការសវនកម្មនោះ ប្រព្រឹត្តទៅបានល្អប្រសើរ ។

**ប្រការ ១៦**: ទីចាត់ការគយ និងរដ្ឋាករ រតនាគារជាតិ នាយកដ្ឋានពន្ធដារ ត្រូវបានបង្កើតការិយាល័យត្រួតពិនិត្យសវនកម្មផ្ទៃក្នុង សំរាប់ធ្វើសវនកម្មផ្ទៃក្នុងរបស់ខ្លួន ។ ការិយាល័យនេះត្រូវបង្កើតដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ រាល់គោលការណ៍ និងកិច្ចដំណើរការរបស់ការិយាល័យរបស់សវនកម្មផ្ទៃក្នុង ត្រូវស្របតាមប្រកាសនេះ ។

**ប្រការ ១៧** : ភារកិច្ចទាំងឡាយណាដែលពាក់ពន្ធ័នឹងសមត្ថកិច្ចរបស់នាយកដ្ឋាន ឬ អង្គភាពជំនាញនៃសវនកម្មផ្ទៃក្នុង ឬ អគ្គាធិការដ្ឋាន ត្រូវសហការជាមួយអង្គភាពពាក់ព័ន្ធនោះ និង សុំគោលការណ៍ ពីថ្នាក់ដឹកនាំក្រសួង ដើម្បីដោះស្រាយ ។

**ប្រការ ១៨** : ប្រកាស ឬ លិខិតបទដ្ឋានទាំងឡាយ ដែលផ្ទុយពីសេចក្តីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១៩** : អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃអចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០២

**គាត ឈន់**

ចម្លងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន រដ្ឋលេខាធិការដ្ឋាន
- អាជ្ញាធរសវនកម្មជាតិ

" ដើម្បីជូនជ្រាបជាពត៌មាន "

- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ : ២៤៤ សហវ.ព្រក.ឧស

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០០២

## ប្រកាស
## ស្តីពី
## ការបែងចែកផលដែលបានមកពីប្រតិបត្តិការបង្ក្រាបអំពើរត់គេចពន្ធ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នរ / រកម / ០១.៩៩ / ០១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៩
- បានឃើញក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ១៩៨៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ និងនាំចូល
- បានឃើញ លិខិតបញ្ជាលេខ ០២ បប ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីវិធានការបង្កើនប្រសិទ្ធភាពក្នុងការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ
- បានឃើញ ប្រកាសលេខ ០០៩ កហវ ចុះថ្ងៃទី០៦ ខែ មេសា ឆ្នាំ១៩៩៣ របស់ក្រសួងហិរញ្ញវត្ថុ ស្តីពីការណែនាំអនុវត្តកិច្ចការផ្តល់ ការបែងចែកប្រាក់រង្វាន់
- យោងតាមសំណូមពរការងារចាំបាច់ក្នុងការបង្កើនប្រសិទ្ធភាពនៃការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ

## សំរេច

**ប្រការ ១** : ត្រូវបានកំណត់ជាផលដែលបានមកពីប្រតិបត្តិការបង្ក្រាបអំពើរត់គេចពន្ធ បណ្តាប្រភពចំណូលណាមួយ ដែលបានមកពីប្រភពដូចខាងក្រោម ៖

១- ទឹកប្រាក់ពន្ធ អាករ ពិន័យ និងកំរៃនានា ដែលជាផលបង្ក្រាបអំពើរត់គេចពន្ធ ដែលទទួលបានក្រោយពេលមានការសំរេចវិនិច្ឆ័យពីស្ថាប័នមានសមត្ថកិច្ចលើករណីល្មើសនីមួយៗ ។

២- ទឹកប្រាក់ដែលបានមកពីការលក់ឡាយឡុងទំនិញ ឬ មធ្យោបាយល្មើស ដែលរឹបអូសស្របតាមច្បាប់ជាធរមានឬដែលជនល្មើសបានប្រគល់ដោយស្ម័គ្រចិត្តនូវទំនិញឬមធ្យោបាយល្មើសនោះដល់រដ្ឋ។

**ប្រការ ២** : ទឹកប្រាក់នៃផលដែលបានមកពីប្រតិបត្តិការបង្ក្រាបអំពើរត់គេចពន្ធ ត្រូវបានកំណត់បែងចែកជាបណ្ដោះអាសន្នដូចខាងក្រោម ៖

១- ៦០ ភាគរយ នៃផលសរុប ត្រូវបង់ចូលថវិការដ្ឋ ។

២- ៣០ ភាគរយ នៃផលសរុប ជាប្រាក់រង្វាន់លើកទឹកចិត្តដល់បុគ្គលនានាដែលមានស្នាដៃក្នុងការចូលរួមប្រតិបត្តិការបង្ក្រាបអំពើរត់គេចពន្ធ ។

៣- ១០ ភាគរយ នៃផលសរុប ត្រូវបង់ចូលបេឡាមូលនិធិបង្ក្រាបអំពើរត់គេចពន្ធ ។

**ប្រការ ៣** ត្រូវបានជូនរង្វាន់លើកទឹកចិត្តដល់បុគ្គលទាំងឡាយណាដែលបានចូលរួមក្នុងការផ្ដល់ដំណឹង ការតាមដានស្រាវជ្រាវត្រួតពិនិត្យ និងបង្ក្រាបអំពើរត់គេចពន្ធដែលនាំឱ្យរកឃើញ និងបង្ក្រាបបាននូវបទល្មើសគយតាមគ្រប់រូបភាព ។

**ប្រការ ៤** : ទឹកប្រាក់រង្វាន់លើកទឹកចិត្តដូចមានចែងក្នុងចំណុច ០២ ប្រការ ០២ ខាងលើនេះ ត្រូវបានបែងចែកដូចខាងក្រោម ៖

១- ចំនួនប្រាក់ ៥០ ភាគរយ នៃប្រាក់រង្វាន់សរុប សំរាប់ផ្ដល់ចំពោះបុគ្គលដែលបានចូលរួមក្នុងប្រតិបត្តិការបង្ក្រាបអំពើរត់គេចពន្ធដោយផ្ទាល់ ។

២- ចំនួនប្រាក់ ១០ ភាគរយ នៃប្រាក់រង្វាន់សរុប សំរាប់ផ្ដល់ចំពោះអ្នកផ្ដល់ពត៌មានដែលនាំឱ្យរកឃើញនូវបទល្មើសនេះ ។ ក្នុងករណីពុំមានអ្នកផ្ដល់ពត៌មាន ទឹកប្រាក់នេះត្រូវបន្ថែមជូនជាប្រាក់រង្វាន់ ចំពោះបុគ្គលដែលបានចូលរួមដោយផ្ទាល់ក្នុងប្រតិបត្តិការបង្ក្រាបអំពើរត់គេចពន្ធដូចមានចែងក្នុងចំណុច ០១ នៃប្រការនេះ ។

៣- ចំនួនប្រាក់ ១០ ភាគរយ នៃប្រាក់រង្វាន់សរុបសំរាប់ប្រើប្រាស់ដើម្បីផ្ដល់ជូនដល់បុគ្គលដែលបានចូលរួមធ្វើអន្តរាគមន៍ដោយប្រយោលផ្សេងទៀត ។

៤- ចំនួនប្រាក់ ១៥ ភាគរយ នៃទឹកប្រាក់រង្វាន់ដែលនៅសល់ ត្រូវបែងចែកដូចតទៅ ៖

- ០៥ ភាគរយ សំរាប់ឧបត្ថម្ភកិច្ចដំណើរការទីស្នាក់ការគយនិងរដ្ឋាករដែលមានស្នាដៃ ។
- ០៥ ភាគរយ សំរាប់ឧបត្ថម្ភកិច្ចដំណើរការការិយាល័យ សាខាគយនិងរដ្ឋាករ ដែលគ្រប់គ្រងទីស្នាក់ការគយនិងរដ្ឋាករ ។
- ០៥ ភាគរយ សំរាប់ឧបត្ថម្ភកិច្ចដំណើរការរបស់ទីចាត់ការគយនិងរដ្ឋាករទាំងមូល ។

ក្នុងករណីដែលទំនិញល្មើសនោះ ត្រូវបង្ក្រាបបានដោយការិយាល័យ ឬ សាខាគយនិងរដ្ឋាករ ប្រាក់រង្វាន់ ១៥ ភាគរយ ដែលចែងក្នុងចំណុច ០៤ នៃប្រការនេះ ត្រូវបែងចែកដូចខាងក្រោម៖

- ០៥ ភាគរយ សំរាប់ឧបត្ថម្ភកិច្ចដំណើរការរបស់ការិយាល័យ សាខាគយនិងរដ្ឋាករសាមុី ដែលមានស្នាដៃ ។
- ១០ ភាគរយ សំរាប់ឧបត្ថម្ភកិច្ចដំណើរការរបស់ទីចាត់ការគយនិងរដ្ឋាករទាំងមូល ។

៥- ចំនួនប្រាក់ ១៥ ភាគរយ នៃប្រាក់រង្វាន់សរុប សំរាប់ឧបត្ថម្ភកិច្ចដំណើរការរបស់អង្គភាព ឬ/ និងអាជ្ញាធរដែនដីដែលបានចូលរួមបង្កើតស្នាដៃក្នុងប្រតិបត្តិការបង្ក្រាបអំពើរត់គេចពន្ធ។ ក្នុងករណីដែលការរកឃើញបទល្មើសច្បាប់គយ ពុំមានការចូលរួមពីភ្នាក់ងារគយនិងរដ្ឋាករ

ឬពុំមានអន្តរាគមន៍ពីអង្គភាព ឬ អាជ្ញាធរដែនដីនោះទេ ទឹកប្រាក់រង្វាន់ ដែលបែងចែកក្នុងចំណុច ០៤ ឬចំណុច ០៥ នៃប្រការនេះត្រូវបង់ចូលបេឡាមូលនិធិបង្ក្រាបអំពើរត់គេចពន្ធ ។ ក្នុងករណីទឹកប្រាក់ដែលត្រូវផ្តល់រង្វាន់សរុបលើសពី ១០០ លានរៀល ការបែងចែកត្រូវមានការសំរេចជាមុនពីរាជរដ្ឋាភិបាល ។

<u>ប្រការ ៥</u> : មូលនិធិបង្ក្រាបអំពើរត់គេចពន្ធដែលមានចែងក្នុងចំណុច ០៣ នៃប្រការ០២ ខាងលើត្រូវគ្រប់គ្រងដោយទីចាត់ការគយនិងរដ្ឋាករ សំរាប់បំរើឱ្យការចំណាយបណ្តោះអាសន្នមុនក្នុងករណីចាំបាច់ រួចទូទាត់បញ្ចូលវិញក្នុងប្រតិបត្តិការនិមួយៗ និងសំរាប់ទូទាត់ចំណាយក្នុងប្រតិបត្តិការណាដែលពុំទទួលបានផល ឬ ទទួលបានផលពុំគ្រប់គ្រាន់សំរាប់បំរើការចំណាយជាក់ស្តែង ។ ទឹកប្រាក់មូលនិធិបង្ក្រាបអំពើរត់គេចពន្ធ ត្រូវប្រើប្រាស់តែលើការចំណាយចាំបាច់ និងបន្ទាន់នានារួមមាន ការហូបចុក ការស្នាក់នៅ ការទិញប្រេងឥន្ធនៈសំរាប់មធ្យោបាយដឹកជញ្ជូន និងការជួលមធ្យោបាយដឹកជញ្ជូនបំរើឱ្យប្រតិបត្តិការក្នុងករណីចាំបាច់ប៉ុណ្ណោះ ។ ការចំណាយតាមតំរូវការផ្សេងទៀតខុសពីមុខសញ្ញាទាំងនេះ ត្រូវមានការឯកភាពជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

<u>ប្រការ ៦</u> : បណ្តាការចំណាយនានាពាក់ពន្ធ័នឹងការថែរក្សា សន្និធិ លើកដាក់ ផ្ទេរផ្ទួរ និងការដឹកជញ្ជូនទំនិញឬមធ្យោបាយល្មើសជាបន្ទុករបស់ម្ចាស់ ឬ តំណាងម្ចាស់ទំនិញឬមធ្យោបាយល្មើស ។

<u>ប្រការ ៧</u> : សំរាប់ប្រតិបត្តិការស្រាវជ្រាវបង្ក្រាបអំពើរត់គេចពន្ធមានលក្ខណៈលំបាកស្មុគស្មាញខ្លាំង ដែលត្រូវចំណាយកំលាំងពលកម្មធនធានសំភារៈច្រើន និងរយៈពេលយូរផងនោះ ទីចាត់ការគយនិងរដ្ឋាករ ត្រូវធ្វើសំណើអមដោយរបាយការណ៍ច្បាស់លាស់ ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីសុំការពិនិត្យ និងសំរេចជូនប្រាក់រង្វាន់ក្នុងកំរិតខ្ពស់សមរម្យមួយ ជាករណីពិសេស ។

<u>ប្រការ ៨</u> : ប្រកាសទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ នឹងត្រូវចាត់ទុកជានិរាករណ៍ ។

<u>ប្រការ ៩</u> : ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា នាយកទីចាត់ការគយនិងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានព្រមទាំង អង្គភាពពាក់ពន្ធ័នានាក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុព្រមទាំងបុគ្គល និងស្ថាប័នពាក់ពន្ធ័ផ្សេងទៀត ត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

<u>**ចម្លងជូន**</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី ( ដើម្បីជូនជាពត៌មាន )
- ទីចាត់ការគយនិងរដ្ឋាករ
- សភាពាណិជ្ជកម្ម ( ដើម្បីសហការផ្សព្វផ្សាយនិងអនុវត្ត )
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ១៣១ ឧ.ក.ស.ប្រក

រាជធានី-ភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០២

## ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ. ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩១ ស្តីពីការគ្រប់គ្រងឧស្សាហកម្មតូច និង សិប្បកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញប្រកាសលេខ ៦១ ផក.ប្រក ចុះថ្ងៃទី ២២-០១-៩៩ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- យោងពាក្យស្នើសុំ បន្តដំណើរការសិប្បកម្មផលិតគ្រឿងអលង្ការក្រឡៃគ្រប់ប្រភេទរបស់លោក HUANG YU LIU ចុះថ្ងៃទី២១-០១-០២ ។

## សំរេច

**ប្រការ១:-** អនុញ្ញាតអោយសិប្បកម្មផលិតគ្រឿងអលង្ការក្រឡៃគ្រប់ប្រភេទ ដែលមានលោក HUANG YU LIU ជនជាតិចិន (តៃវ៉ាន់) កាន់លិខិតឆ្លងដែនលេខ M17166399 ចុះថ្ងៃទី ១៥-១២-៩៩ ជាតំណាងក្រុមហ៊ុន " ADVANCED INDUSTY Co., LTD " អាស័យដ្ឋានស្នាក់នៅបច្ចុប្បន្ន ផ្ទះលេខ ២១៥ ផ្លូវលេខ ១៦៤ សង្កាត់ ទឹកល្អក់ទី២ ខ័ណ្ឌ ទួលគោក រាជធានី ភ្នំពេញ បន្តដំណើរការផលិតកម្ម នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

**ប្រការ២:-** ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

**ប្រការ៣:-** អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និង លោក HUANG YU LIU ត្រូវទទួលអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន ។

**ប្រការ៤:-** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ចំលងជូន:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុង ភ្នំពេញ
- ខ័ណ្ឌ ទួលគោក
  "ដើម្បីជ្រាប"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ស៊ុយ_សែម